កិច្ចការ១៩:៨-២០:៤

**[៨] ប៉ុលក៏ចូលទៅអធិប្បាយ ក្នុងសាលាប្រជុំ ដោយក្លាហាន ហើយ**
**ក្នុងរវាង៣ខែ គាត់ចេះតែជជែកពន្យល់ ព្រមទាំងបញ្ចុះបញ្ចូលគេ**
**ឱ្យជឿតាមអស់ទាំងសេចក្តីពីនគរព្រះ [៩] លុះកាលអ្នកខ្លះកើតមាន**
**ចិត្តរឹងទទឹង ហើយចចេស ព្រមទាំងនិយាយអាក្រក់ពីផ្លូវនោះ**
**នៅមុខប្រជាជន នោះគាត់ក៏ថយចេញពីគេទៅ ញែកយកទាំងពួក**
**សិស្សទៅផង រួចគាត់ជជែកពន្យល់ក្នុងសាលាបង្រៀនរបស់ទី**
**រ៉ានុសជារាល់ថ្ងៃ [១០] គាត់ធ្វើដូច្នោះ អស់២ឆ្នាំ ដល់ម្ល៉េះបានជា**
**អស់អ្នក ដែលនៅស្រុកអាស៊ី បានឮព្រះបន្ទូលនៃព្រះអម្ចាស់**
**ទាំងសាសន៍យូដា នឹងសាសន៍ក្រេកផង (កិច្ចការ១៩:៨-១០)។**

សាវ៉កប៉ុលចាំបាច់ត្រូវចាកចេញពីសាលាប្រជុំរបស់សាសន៍យូដា ពីព្រោះនៅទីនោះ មានការប្រឆាំងទាស់នឹងលោកយ៉ាងខ្លាំង។ លោករើទីកន្លែងបង្រៀនពីសាលាប្រជុំទៅបង្រៀននៅសាលារៀនសាធារណៈមួយឈ្មោះទីរ៉ានុស។

សាលាទីរ៉ានុស គឺជាសាលារៀនសាធារណៈសម្រាប់បង្រៀនដល់អ្នកក្រុងអេភេសូរ។ នៅក្នុងសាលារៀនសាធារណៈធម្មតាគេមិនប្រើ សាលារៀនចន្លោះម៉ោងដប់មួយទៅម៉ោងពីរទេ។ សាវ៉កប៉ុលជួលសាលាទីរ៉ានុស មួយថ្ងៃបីម៉ោង ដើម្បីបង្ហាត់

បង្រៀនព្រះបន្ទូល។ លោកបង្រៀនព្រះបន្ទូលនៅទីក្រុងអេភេសូរអស់រយៈពេលពីរឆ្នាំ។ ជាលទ្ធផល ខេត្តអាស៊ីទាំងមូលបានឮព្រះបន្ទូលរបស់ព្រះ។ អ្នកស្រុកនៅខេត្តអាស៊ីមានទាំងសាសន៍យូដានិងសាសន៍ក្រេកផងបានជឿដែរ។

នៅក្នុងទីក្រុងអេភេសូរ ព្រះបន្ទូលរបស់ព្រះចម្រើនឡើងដោយសារមានមនុស្សបង្ហាត់បង្រៀនដល់អ្នកដទៃទៀត។ ការបង្ហាត់បង្រៀនព្រះបន្ទូលនៅទីក្រុងអេ-ភេសូរអស់រយៈពេលពីរឆ្នាំ បណ្តាលអោយមានក្រុមជំនុំកើតឡើងនៅទីក្រុងផ្សេងៗមានក្រុងកូល៉ុសជាដើម។ សាវ័កប៉ុលសរសេរសំបុត្រទៅពួកជំនុំនៅទីក្រុងកូល៉ុស និងទីក្រុងរ៉ូម មុនលោកបានធ្វើដំណើរទៅទីនោះផង។ សាវ័កប៉ុលបង្ហាត់បង្រៀនព្រះបន្ទូលរបស់ព្រះអង្គនៅសាលាទីរ៉ានុស នាទីក្រុងអេភេសូរ។ ព្រះបន្ទូលរបស់ព្រះក៏រីកសាយចាប់តាំងពីទីកន្លែងនោះទៅ។ នៅពេលដែលពួកជំនុំនៅទីក្រុងកូរិនថូសចង់អោយសាវ័កប៉ុលចុះទៅ ដើម្បីបង្ហាត់បង្រៀនគេបន្ថែមទៀត លោកសរសេរសំបុត្រទៅកាន់ពួកជំនុំទាំងនោះថា "ដ្បិតខ្ញុំមិនចូលចិត្ត មកសួរអ្នករាល់គ្នាតាមផ្លូវឥឡូវនេះទេ តែខ្ញុំសង្ឃឹមថានឹងមកនៅជាមួយនឹងអ្នករាល់គ្នាជាយូរបន្តិច បើសិនជាព្រះអម្ចាស់ទ្រង់អនុញ្ញាតឱ្យ។ ប៉ុន្តែ ខ្ញុំនឹងនៅក្រុងអេភេសូរទាល់តែដល់បុណ្យថ្ងៃទី៥០ ដ្បិតមានទ្វារយ៉ាងធំហើយស្រួលបានបើកចំហឱ្យខ្ញុំ ហើយក៏មានពួកឃាត់ឃាំងជាច្រើនដែរ" (១កូរិនថូស១៦:៧-៩)។

អស់រយៈពេលពីរឆ្នាំគត់ ដែលដំណឹងល្អបានរីកសុសសាយនៅក្នុងខេត្តអាស៊ី។ បើតាមការសន្និដ្ឋាន ក្រុមជំនុំទាំងប្រាំពីរនៅទ្វីបអាស៊ីចុងខាងលិច បានកើតឡើងដោយ

សារដំណឹងល្អដែលសាវ័កប៉ុលបង្ហាត់បង្រៀននៅទីក្រុងអេភេសូរនេះដែរ។ កិច្ចការរបស់សាវ័កប៉ុល មានទំហំធំធេងខ្លាំងណាស់ ពីទីក្រុងអេភេសូរ។

**ហើយព្រះទ្រង់ធ្វើការឫទ្ធិបារមីយ៉ាងប្លែកៗ ដោយសារដៃប៉ុល (កិច្ចការ១៩:១១)។**

ពាក្យថា "ឫទ្ធិបារមី" ជាភាសាក្រេកហៅថា ឌូណាមីស ដែលប្រែថា ថាវ ឬរំសេវ។ ព្រះជាម្ចាស់ធ្វើការតាមរយៈសាវ័កប៉ុល មានកម្លាំងផ្ទុះដូចថាវ។ សាវ័កប៉ុលអាចធ្វើការនេះបាន ពីព្រោះព្រះជាម្ចាស់ប្រទានអំណោយទានដល់លោកក្នុងនាមលោកជាសាវ័កមួយរូបក្នុងចំណោមសាវ័កទាំងដប់ពីររូប។

ទីក្រុងអេភេសូរ គឺជាមជ្ឈមណ្ឌលសាសនា ដែលធំជាងទីក្រុងអាថែនទៅទៀត។ ព្រះវិហារឌីអាន ដែលជាវិហារធំបំផុត បានសង់នៅទីនោះ។ ឯការថ្វាយបង្គំសាតាំងក៏ខ្លាំងដល់កម្រិតនៅក្នុងទីក្រុងនោះដែរ។ ដូច្នេះ ហើយបានជាព្រះជាម្ចាស់ចាំបាច់ផ្ដល់ចេស្ដាដល់សាវ័កប៉ុល អោយអាចធ្វើឫទ្ធិបារមីបាន ដើម្បីតទល់ជាមួយនឹងសេចក្ដីប្រឆាំងយ៉ាងខ្លាំង កើតមាននៅក្នុងទីក្រុងដ៏ធំនេះ។

**ដល់ម៉្លេះបានជាគេគ្រាន់តែយកកន្សែង ឬក្រមា ពីខ្លួនគាត់ ទៅដាក់លើមនុស្សមានជំងឺ នោះគេក៏បានជា ហើយមានអារក្ស**

**អាសោចិ៍ចេញពីមនុស្សដែរ (កិច្ចការ១៩:១២)។**

ក្រមាដែលនិយាយនៅក្នុងខនេះ គឺជាក្រមាដែលសាវ៉កប៉ុលប្រើសម្រាប់ជូតញើស។ សាវ៉កប៉ុលប្រកបរបររកស៊ីជាអ្នកសង់ត្រសាល ក្រៅអំពីការបម្រើព្រះអង្គ។ ពេលលោកធ្វើការហាលថ្ងៃ លោកបែកញើសយ៉ាងខ្លាំង។ លោកយកក្រមានោះ ដើម្បីជូតញើស។ ក្រមាដែលជូតញើស ក្លិនមិនល្អទេ។ ប៉ុន្តែ ទោះបីយ៉ាងនោះក៏ដោយ មានមនុស្សឈឺយកក្រមាស្អុយញើសរបស់សាវ៉កប៉ុលប្រោសជម្ងឺរបស់ខ្លួន។ នៅក្នុងទីក្រុងអេភេសូរគេជឿថា ដើម្បីព្យាបាលរោគ គេត្រូវយកក្រណាត់សស្អាត ឥតមានប្រឡាក់អ្វីបន្តិចបន្តួចទៅប្រើ ដើម្បីព្យាបាលជម្ងឺ។ ព្រះជាម្ចាស់ចង់បង្ហាញដល់អ្នកស្រុកនោះថា ក្រណាត់ស្អាតមិនធានាថា ពិតជាមានអំណាចទេ។ ព្រះអង្គអោយសាវ៉កប៉ុលប្រើក្រមាស្អុយញើសរបស់លោក ដើម្បីប្រោសជម្ងឺដល់មនុស្សលោក។

ឥឡូវសូមយើងពិចារណាអំពីខ្លឹមសារនៃការប្រើក្រមានេះបន្តិច។ ព្រះជាម្ចាស់ប្រើសាវ៉កប៉ុល ដើម្បីអោយយកក្រមារបស់លោកប្រោសជម្ងឺ។ អំណាចពិតប្រាកដគឺស្ថិតនៅលើព្រះជាម្ចាស់ទេ។ សាវ៉កប៉ុលនិងក្រមា គ្រាន់តែជាយានសម្រាប់ធ្វើអោយចេស្តារបស់ព្រះជាម្ចាស់ធ្លាក់ទៅដល់ជនដែលរងគ្រោះ។ នៅក្នុងក្រមាមិនមានអំណាចអ្វីទាល់តែសោះ។ ក្រមាទោះល្អ ឬអាក្រក់ក្តី ត្រូវការចេស្តា ឯចេស្តាពិតប្រាកដ គឺជាចេស្តារបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

**រីឯមានមនុស្សសាសន៍យូដាខ្លះ ជាគ្រូមន្តអាគម ដែលដើរចុះឡើង គេក៏ចាប់តាំងអំពាវនាវ ដល់ព្រះនាមព្រះអម្ចាស់យេស៊ូវ ពីលើមនុស្សដែលមានអារក្សអសោចិ៍ចូលថា អញបង្គាប់ឯង ដោយនូវព្រះយេស៊ូវ ដែលប៉ុលប្រកាសប្រាប់នោះ (កិច្ចការ១៩:១៣)។**

មានគ្រូមន្តអាគមជាច្រើន ឃើញសាវ័កប៉ុលប្រើក្រមារបស់លោក ដើម្បីប្រោសជម្ងឺដល់មនុស្សលោក។ លុះគេឃើញមានហេតុការណ៍កើតឡើងអស្ចារ្យយ៉ាងដូច្នោះ គេក៏មាននាំគ្នាធ្វើត្រាប់តាមសាវ័កប៉ុល។ ឯលទ្ធផលគេក៏បានជាទីគាប់ចិត្ត គឺសេចក្តីខ្មាស់អៀនយ៉ាងខ្លាំង។

**[១៤]ក្នុងពួកមនុស្សដែលធ្វើដូច្នោះ មាន៧នាក់ ជាកូននៃសាសន៍យូដាម្នាក់ ដែលធ្វើជាសង្គ្រាជឈ្មោះស្កេវ៉ា [១៥]តែអារក្សអសោចិ៍ឆ្លើយទៅគេថា យើងស្គាល់ព្រះយេស៊ូវហើយ ក៏ស្គាល់ប៉ុលបន្តិចបន្តួចដែរ តែឯឯងរាល់គ្នា តើជាអ្នកណាវិញ (កិច្ចការ១៩:១៤-១៥)។**

សូមលោកអ្នកកត់ចំណាំអំពីនាទីរបស់មនុស្ស ដែលប្រើមន្តអាគមនៅក្នុងខខាងលើ។ មនុស្សទាំងអម្បាលមាណដែលចេះប្រើមន្តអាគមនោះ មាននាទីជាសង្ឃ

ផង។ ធម្មតាក្នុងនាមខ្លួនជាសង្ឃ មិនត្រូវប្រើមន្តអាគមអូមអាមអ្វីទេ តែសង្ឃទាំងនោះនាំគ្នាយកមន្តអាគមមកធ្វើជាត្រីមុខ។ អារក្សបានប្រើពាក្យថា "...យើងស្គាល់ព្រះយេស៊ូវ ហើយក៏ស្គាល់ប៉ុលបន្តិចបន្តួចដែរ..."។ ពាក្យថា "ស្គាល់" នៅក្នុងភាសាក្រេក គឺ ហ្គីណូស្កូ។ ពាក្យនេះ មិនមែនមានន័យថា ស្គាល់ដោយមានជំនឿនោះទេ គឺពាក្យនេះគ្រាន់តែមានន័យថា "ស្គាល់" ប៉ុន្តែមិនបានយល់ពីហេតុដែលគេស្គាល់នោះឡើយ។ សាតាំងស្គាល់ព្រះយេស៊ូវនិងស្គាល់សាវ៉កប៉ុល តែមិនមែនមានន័យថា សាតាំងជឿដល់ព្រះយេស៊ូវទេ។

> **រួចមនុស្សដែលមានអារក្សអសោចិ៍ចូលក៏ស្ទុះទៅលើគេ ទាំងបង្ក្រាប ហើយឈ្នះគេ ដល់ម៉្លេះបានជាគេរត់ចេញពីផ្ទះនោះទាំងអាក្រាត ហើយមានរបួសផង (កិច្ចការ១៩:១៦)។**

ការព្យាយាមធ្វើត្រាប់តាមទីសម្គាល់របស់សាវ៉កប៉ុល បណ្ដាលអោយកូនរបស់លោកស្កេវ៉ាទទួលរងគ្រោះយ៉ាងដំណំ។ ការរងគ្រោះបែបនោះ បណ្ដាលអោយពួកសង្ឃទាំងនោះមានការខ្មាស់អៀនយ៉ាងខ្លាំង។

> **ឯអស់មនុស្សនៅក្រុងអេភេសូរ ទាំងសាសន៍យូដា នឹងសាសន៍ក្រេកផង បានដឹងរឿងនោះ ក៏កើតមានចិត្តភ័យខ្លាចទាំងអស់គ្នា**

**ហើយព្រះនាមព្រះអម្ចាស់យេស៊ូវក៏បានថ្កើងឡើង (កិច្ចការ ១៩:១៧)។**

ហេតុការណ៍ដែលកើតឡើងដល់ពួកកូនចៅលោកស្កេវ៉ា ធ្វើអោយទីក្រុងអេភេសូរទាំងមូលមានការកក្រើករំពើក។ ព្រះនាមរបស់ព្រះអម្ចាស់យេស៊ូវត្រូវ ពួគេនិយាយទូទៅនៅក្នុងទីក្រុងនេះ។ ទីក្រុងអេភេសូរ គឺជាទីក្រុងដ៏ធំ ត្រូវរំជួយដោយសារព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

ទីសម្គាល់ដែលសាវ័កប៉ុល ហើយនិងសាវ័កដទៃៗទៀតបានធ្វើនោះ ធ្វើអោយគ្រឹះសំណង់គ្រប់បែបយ៉ាងត្រូវរង្គើនៅក្នុងទីក្រុងអេភេសូរទាំងមូល។ ដោយសារមូលហេតុនោះ ព្រះនាមរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ បានទទួលការដំកើងឡើងខ្ពស់ជាទីបំផុត។

**[១៨]មានមនុស្សជាច្រើនដែលបានជឿ គេមកលន់តួ ព្រមទាំងសំដែងប្រាប់ ពីការដែលខ្លួនបានប្រព្រឹត្តផង [១៩]ឯមនុស្សដែលប្រព្រឹត្តវិជ្ជាប្លែកៗ នោះក៏មានច្រើននាក់ បានយកក្បួនដំរារបស់ខ្លួន មកដុតចោលនៅចំពោះមុខមនុស្សទាំងអស់គ្នា គេបានគិតថ្លៃក្បួនទាំងនោះមើល ឃើញមានដំឡៃអស់៥ម៉ឺនរៀល (កិច្ចការ ១៩:១៨-១៩)។**

តើ៥០០០០រៀលនៅក្នុងសម័យនោះ ត្រូវជាចំនួនប៉ុន្មានដុល្លា ក្នុងឆ្នាំ១៩៦០? ៥០០០០រៀលក្នុងឆ្នាំ១៩៦០មានតម្លៃស្មើនឹង៨០០០ដុល្លាសហរដ្ឋអាមេរិក។ គេនាំគ្នាយកគ្រឿងសក្ការៈថ្វាយបង្គំ ដែលមានតម្លៃចំនួន៨០០០ដុល្លាយកមកដុតចោល។ ការនេះកើតឡើងនៅក្នុងទីក្រុងអេភេសូរ។

> **[២០]គឺយ៉ាងដូច្នោះឯង ដែលព្រះបន្ទូលនៃព្រះអម្ចាស់បានចំរើនកើនឡើង ហើយបានឈ្នះដោយអំណាច [២១]ក្រោយការទាំងនោះមក ប៉ុលគិតសំរេចក្នុងចិត្ត ថាកាលណាបានដើរកាត់ស្រុកម៉ាសេដូន នឹងស្រុកអាខៃហើយ នោះគាត់នឹងទៅឯក្រុងយេរូសាឡិម ក៏និយាយថា ក្រោយដែលខ្ញុំបានទៅឯណោះហើយ នោះត្រូវឲ្យខ្ញុំទៅមើលក្រុងរ៉ូមដែរ (កិច្ចការ១៩:២០-២១)។**

តើពាក្យថា "ក្រោយការទាំងនោះមក" គឺជាការអ្វី? គឺក្រោយការដែលកើតឡើងនៅក្នុងទីក្រុងអេភេសូរ។ ក្រោយការទាំងនោះមក សាវ័កប៉ុលចង់ធ្វើដំណើរបង្ហួសទៅទីក្រុងរ៉ូម។ វត្ថុបំណងរបស់លោកមិនបានសម្រេចក្នុងពេលនេះទេ។ ក្រោយមកទើបវត្ថុបំណងរបស់លោកបានសម្រេចទៅដល់ទីក្រុងរ៉ូមមែន តែមិនមែនដូចលោកគ្រោងទុកពីមុនមកទេ។

**គាត់ចាត់អ្នកជំនួយគាត់២នាក់ គឺធីម៉ូថេ នឹងអេរ៉ាស្ទុស ឱ្យទៅស្រុកម៉ាសេដូន តែខ្លួនគាត់ស្នាក់នៅក្នុងស្រុកអាស៊ីបន្តិចទៀត (កិច្ចការ១៩:២២)។**

ពេលនេះ គឺជាពេលដែលលោកសរសេរសំបុត្រទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ។ លោកធីម៉ូថេ និងលោកអេរ៉ាស្ទុសត្រូវកាន់យកសំបុត្ររបស់សាវ័កប៉ុលដើម្បីអោយទៅដល់ពួកជំនុំនៅទីក្រុងកូរិនថូស។ ទោះបីសំបុត្រនេះលោកសរសេរសម្រាប់ពួកជំនុំនៅទីក្រុងកូរិនថូស តែគេយកមកអានអោយពួកជំនុំនៅស្រុកម៉ាសេដូនស្តាប់ដែរ។ ពួកជំនុំនៅស្រុកម៉ាសេដូន មានពួកជំនុំទីក្រុងភីលីព និងពួកជំនុំថែស្សាឡូនីច។ ឯក្រុមជំនុំនៅស្រុកអាខៃ ដែលមានក្រុមជំនុំអាថែន និងក្រុមជំនុំទីក្រុងកូរិនថូស ក៏បានស្តាប់សេចក្តីដែលបានចែងនៅក្នុងសំបុត្រនោះដែរ។ នៅក្នុងសំបុត្រនោះ សាវ័កប៉ុលបញ្ជាក់ថា មានទ្វារបើកចំហសម្រាប់លោកនៅទីក្រុងអេភេសូរ តែក៏មានអ្នកប្រឆាំងច្រើននាក់ណាស់ដែរ។ យើងឃើញថា អ្នកដែលប្រឆាំងខ្លាំងជាងគេនៅក្នុងទីក្រុងអេភេសូរ គឺអ្នកដែលបម្រើអារក្សសាតាំង។ ទីក្រុងអេភេសូរ គឺជាមជ្ឈមណ្ឌលសាសនាយ៉ាងធំ រួមទាំងការថ្វាយបង្គំដល់សាតាំងផង។ ការថ្វាយបង្គំសាតាំងដែលយើងឃើញក្នុងពេលសព្វថ្ងៃនេះ មិនមែនទើបនឹងកើតថ្មីៗនេះទេ។

**នៅគ្រានោះ កើតមានវឹកវរជាធំ ពីដំណើរផ្លូវនោះ (កិច្ចការ១៩:**

២៣)។

សម័យដើម ក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រិស្ត មិនទាន់មានឈ្មោះអ្វីអោយបានត្រឹមត្រូវឡើយ។ ឯឈ្មោះនិកាយក៏មិនទាន់មានដែរ។ គេនាំគ្នាហៅអ្នកជឿព្រះយេស៊ូវថា ជាអ្នកដើរតាម "ផ្លូវនោះ"។ ផ្លូវនោះ គឺគេនិយាយសំដៅទៅលើព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន ១៤:៦ថា "...ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណា ទៅឯព្រះវរបិតាបានឡើយ"។

**ដ្បិតមានមនុស្សម្នាក់ឈ្មោះដេមេទ្រាស ជាជាងប្រាក់ដែលធ្វើអាស្រមព្រះឌីអានពីប្រាក់ គាត់ជួយដល់ពួកជាងទាំងប៉ុន្មាន ឱ្យបានកំរៃជាច្រើន (កិច្ចការ១៩:២៤)។**

វិហាររបស់ព្រះឌីអាន ជាវិហារដែលមានធំ ព្រមទាំងមានរូបចម្លាក់ក្បាច់រចនាយ៉ាងរស់រវើក។ វិហារនេះជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ពោលគឺ ប្រៀបឧបមាថាដូចជាធនាគារនៅក្នុងពេលសព្វថ្ងៃនេះដែរ។ វិហារឌីអានមិនមែន គ្រាន់តែជាមជ្ឈមណ្ឌលពាណិជ្ជកម្មទេ ប៉ុន្តែជាមជ្ឈមណ្ឌលសាងបាបកម្មថែមទៀតផង។ នៅក្នុងវិហារព្រះឌីអានមានការប្រព្រឹត្តអំពើស្មោកគ្រោក ដូចជាប្រើអំពីកាមគុណ ដើម្បីសម្រេច

ជំនឿជាដើម។ វិហារនេះជាវិហារដែលជាប់ក្នុងចំណោមប្រាង្គប្រាសាទទាំងប្រាំពីរនៅលើលោកយើងនេះ។ ដោយសារវិហារឌីអានជាវិហារធំ បានជាពួកជាងទងនាំគ្នាយកវិហារនោះធ្វើជារបររកស៊ី។ នៅពេលសាវ័កប៉ុលផ្សព្វផ្សាយដំណឹងល្អរបស់ព្រះយេស៊ូវដល់អ្នកស្រុកនៅទីក្រុងអេភេសូរ របររកស៊ីរបស់ជាងទងទាំងអម្បាលមាណមានការធ្លាក់ចុះដុនដាបយ៉ាងខ្លាំង។

> **២៥ កាលគាត់បានប្រមូលគេ ព្រមទាំងពួកអ្នកដែលមានរបរដូច
> គ្នាទាំងប៉ុន្មានមក នោះគាត់និយាយថា អ្នករាល់គ្នាអើយ
> អ្នកដឹងថា យើងបានផលចំណេញពីរបរនេះមក
> ២៦ អ្នកក៏ឃើញ
> ហើយឮថា ឈ្មោះប៉ុលនេះបានបញ្ចុះបញ្ចូល ព្រមទាំងបង្វែរ
> មនុស្សសន្ធឹកទៅហើយ មិនត្រឹមតែនៅអេភេសូរប៉ុណ្ណោះ គឺស្ទើរ
> តែនឹងគ្រប់សព្វនៅស្រុកអាស៊ីផង ដោយពាក្យថា អស់ទាំងព្រះ
> ដែលដៃមនុស្សធ្វើ នោះមិនមែនជាព្រះទេ
> ២៧ ដូច្នេះ មាន
> អន្តរាយកើតដល់យើង មិនត្រឹមតែសមាគមនេះ ដោយគេលែង
> រាប់អានប៉ុណ្ណោះ គឺក្រែងគេលែងទាំងគោរពប្រតិបត្តិ ដល់ព្រះ
> វិហាររបស់ព្រះឌីអានដ៏ធំ ថែមទៀតផង រូបសិរីល្អនៃព្រះរបស់
> យើង ដែលគ្រប់ស្រុកអាស៊ី នឹងលោកីយទាំងមូលក៏ថ្វាយបង្គំ
> នឹងត្រូវសាបសូន្យទៅ (កិច្ចការ១៩:២៥-២៧)។**

ហេតុអ្វីបានជាពួកជាងទងទាំងអម្បាលមាណ នាំគ្នាដើរតាមលោកដេមេទ្រាស ក្នុងការធ្វើបាតុកម្មប្រឆាំងជាមួយនិងសាវ័កប៉ុលក? បាតុកម្មដ៏ធំនេះកើតឡើងដោយសារតែរឿងក្រពះតែប៉ុណ្ណោះ។ ជាងទងនោះធ្វើរូបព្រះសម្រាប់លក់យកតម្លៃរបររកស៊ីរបស់ជាងលក់រូបព្រះ រកលុយបានយ៉ាងងាយ។ ទេសចរណ៍ជាច្រើនដែលមកពីទីកន្លែងផ្សេងៗលើសកលលោក នាំគ្នាមកទស្សនាវិហារព្រះឌីអាននៅទីក្រុងអេភេសូរ។ លុះគេត្រឡប់ទៅវិញ គេក៏ទិញរបស់របរជាច្រើនដែលធ្វើអោយអ្នកសូនរូបព្រះក្លាយត្រឡប់ទៅជាអ្នកមាន។ នៅពេលសាវ័កប៉ុលផ្សាយដំណឹងល្អមនុស្សឈប់ថ្វាយបង្គំរូបព្រះ ហើយឈ្មួញលក់រូបព្រះ ក៏អស់ការងារធ្វើ។ ដូច្នេះហើយបានជាគេនាំគ្នាធ្វើបាតុកម្ម បណ្តេញសាវ័កប៉ុលចេញពីទីក្រុងរបស់គេ។

វិហារឌីអានជាវិហារដែលមានឥទ្ធិពលនៅលើទ្វីបអាស៊ី។ ទីក្រុងអេភេសូរជាមជ្ឈមណ្ឌលពាណិជ្ជកម្ម មជ្ឈមណ្ឌលសាសនា និងមជ្ឈមណ្ឌលនៃការថ្វាយបង្គំរូបព្រះគ្រប់ប្រភេទ។ មជ្ឈមណ្ឌលនេះស្ថិតនៅលោកខាងកើត និងមជ្ឈឹមបូព៌ា។ កន្លែងនោះ គឺជាកន្លែងដែលលោកខាងកើត ហើយនិងលោកខាងលិចជួបគ្នា។ អ្វីៗទាំងអស់ដែលអាក្រក់ពីទ្វីបទាំងពីរត្រូវមកសម្ងំនៅក្នុងទីក្រុងអេភេសូរ។

**កាលគេឮសេចក្តីនោះហើយ គេក៏មានពេញដោយសេចក្តីកំហឹង ហើយស្រែកប្រកាសថា ព្រះឌីអាននៃពួកក្រុងអេភេសូរយើងទ្រង់ធំវិសេស (កិច្ចការ១៩:២៨)។**

មេដេទ្រាសនាំគ្នាកាន់បដាដើរពេញទីក្រុង រួចហើយស្រែកជ័យឃោសន៍ថា "...ព្រះឱអាននៃពួកក្រុងអេភេសូរយើង ទ្រង់ធំវិសេស!ៗ!"

**២៩ នោះក៏កើតមានវឹកវរពេញក្នុងក្រុង គេស្រុះចិត្តគ្នាចាប់កន្ត្រាក់**
**កៃយុសនឹងអើរីស្តាក ជាអ្នកស្រុកម៉ាសេដូន ដែលដើរដំណើរ**
**ជាមួយនឹងប៉ុល នាំមីម្នាចូលទៅក្នុងរោងជំនុំ ៣០ ឯប៉ុល គាត់**
**គិតចូលទៅឯបណ្តាជនដែរ តែពួកសិស្សមិនព្រមឱ្យទៅទេ**
**(កិច្ចការ១៩:២៩-៣០)។**

ពួកបាតុករនាំគ្នាវាយសង្គ្រប់មកលើក្រុមសាវ័កប៉ុល។ សាវ័កប៉ុលរកកល ហៀបនឹងត្រូវគេសម្លាប់ម្តងទៀត។ លោកមុនគេបានសម្លាប់លោក ពេលលោកផ្សាយដំណឹងល្អនៅស្រុកកាឡាទី ដោយឡែកគឺនៅទីក្រុងលីស្ត្រា។ នៅទីនោះ គេបានគុបលោកសម្លាប់ដោយថ្ម។

**ហើយមានពួកចៅហ្វាយនៅស្រុកអាស៊ីខ្លះ ដែលស្រឡាញ់គាត់ ក៏ចាត់គេមកអង្វរថា សូមកុំឱ្យចូលទៅក្នុងរោងជំនុំនោះឡើយ (កិច្ចការ១៩:៣១)។**

ពួកបាតុករបង្កលក្ខណៈអោយមានការវឹកវរយ៉ាងខ្លាំង នៅក្នុងទីក្រុងអេភេសូរ ឯពួកចៅហ្វាយនៅស្រុកអាស៊ី គឺជាអ្នកដឹកនាំនយោបាយ និងអ្នកដឹកនាំខាងសាសនា សុំកុំអោយសាវ័កប៉ុលនិយាយអ្វីជាមួយនឹងហ្វូងមនុស្ស ដែលកំពុងតែនាំគ្នាធ្វើបាតុកម្ម ដូចជ្រូកពុលនេះឡើយ។ ការនិយាយជាមួយនឹងមនុស្សទាំងហ្វូងមិនមានប្រយោជន៍អ្វីទេ។

> **[៣២]ឯបណ្តាជន ខ្លះស្រែកយ៉ាងនេះ ខ្លះស្រែកយ៉ាងនោះ ដ្បិតមនុស្សក្នុងចំណោមនោះ កំពុងជ្រួលជ្រើមជាខ្លាំង ច្រើនមិនដឹងជាគេប្រជុំគ្នាដោយហេតុអ្វីផង [៣៣]ពួកសាសន៍យូដាក៏ច្រានអ័លេក្សានត្រុស ចេញពីហ្វូងមនុស្សទៅខាងមុខ គាត់ក៏ធ្វើគ្រៀងសំគាល់នឹងដៃ ចង់ដោះសានឹងបណ្តាមនុស្ស (កិច្ចការ១៩:៣២-៣៣)។**

លោកអ័លេក្សានត្រុស គឺជាបុរសម្នាក់ដែលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទតាមរយៈសាវ័កប៉ុលផ្សាយដំណឹងល្អ។

> **កាលគេបានដឹងថា គាត់ជាសាសន៍យូដា គេក៏ស្រែកឡើងព្រមគ្នាចំនួនប្រហែលជា២ម៉ោងថា ព្រះឌីអានទៃពួកក្រុងអេភេសូរយើង**

**ទ្រង់ធំវិសេស (កិច្ចការ១៩:៣៤)។**

ធម្មតាកាលណាមនុស្សនាំគ្នាធ្វើបាតុកម្ម គេមិនដឹងថា គេនាំគ្នាធ្វើអ្វីទេ។ ខ្លះមិនដឹងរឿងអ្វីសោះ ក៏រត់ចូលទៅក្នុងក្រុមដើម្បីស្រែកជេរនឹងគេដែរ។ ពួកធ្វើបាតុកម្មមិនអនុញ្ញាតអោយនរណា និយាយអ្វីដើម្បីបញ្ជាក់រឿងទេ។ គេមិនព្រំអោយលោកអំលេក្សានត្រុសនិយាយអ្វីផង ដ្បិតគេចេះតែស្រែករំអុកថា "...ព្រះឌីអាននៃក្រុងអេភេសូរយើង ទ្រង់ធំវិសេស"។

**៣៥ កាលលោកភូឈ្មួយបានធ្វើបង្អន់ ដល់ហ្វូងមនុស្ស នោះក៏និយាយថា នែ ពួកក្រុងអេភេសូរអើយ តើមានអ្នកឯណាដែលមិនដឹងថា ពួកអ្នកនៅក្រុងនេះ ជាអ្នកថែរក្សាព្រះវិហារនៃព្រះឌីអានដ៏ធំ ដែលធ្លាក់មកពីព្រះសេយ្យូសនោះ ៣៦ ដូច្នេះ ដែលសេចក្តីនោះជាពិតហើយ នោះគួរតែឱ្យអ្នករាល់គ្នាបានធ្វើដោយស្រួលទៅចុះ មិនត្រូវឱ្យធ្វើដោយរលះរលាំងដូច្នេះឡើយ (កិច្ចការ ១៩:៣៥-៣៦)។**

អាជ្ញាធរដែលគ្រប់គ្រងនៅទីក្រុងអេភេសូរសង្កេតឃើញថា ក្បួនបាតុកម្មនេះហួសព្រំដែនច្បាប់ហើយ។ លោកមានប្រសាសន៍ទៅកាន់អ្នកដឹកនាំក្រុមបាតុកម្មថា

"...នែ ពួកក្រុងអេភេសូរអើយ តើមានអ្នកឯណាដែលមិនដឹងថា ពួកអ្នកនៅក្រុងនេះជាអ្នកថែរក្សាព្រះវិហារនៃព្រះឌីអានដ៏ធំ ដែលធ្លាក់មកពីព្រះសេយូសនោះ"។ បើយើងអាចនិយាយជាភាសាសាមញ្ញ យើងអាចនិយាយពាក្យលោកភូឈូយថា "មើលទីក្រុងអេភេសូរយើងមានវិហារដ៏ធំ គឺជាវិហារព្រះឌីអាន។ ពេលនេះមិនមាននរណាម្នាក់អាចបំផ្លាញវិហារព្រះឌីអានបានទេ។ វិហារនោះនៅឈរជ្រងោរ ឥតមាននរណាប៉ះពាល់អ្វីឡើយ"។ សព្វថ្ងៃនេះ វិហារព្រះឌីអានបានរលំរលាយអស់ជាង២០០០ឆ្នាំកន្លងមកហើយ។

> **[៣៧]អ្នករាល់គ្នាបាននាំមនុស្សទាំងនេះមក ដែលមិនមែនជាចោរ**
> **លួចវិហារ ឬប្រមាថដល់ព្រះនៃអ្នករាល់គ្នាទេ [៣៨]ដូច្នេះ បើសិន**
> **ជាដេមេទ្រាស នឹងពួកជាងដែលមកជាមួយគ្នានេះមានរឿង**
> **អ្វីនឹងអ្នកណា នោះមានទីសំរាប់ជំនុំជំរះក្តីស្រាប់ ហើយមានទាំង**
> **ពួកចៅក្រមផង ត្រូវឱ្យគេប្តឹងប្តល់គ្នាទៅចុះ (កិច្ចការ១៩:៣៧-**
> **៣៨)។**

លោកភូឈូយនិយាយទៅកាន់មេដឹកនាំក្រុមបាតុករថា បើពួកជាងទងទាំងនោះ ចង់ចោទប្រកាន់រឿងអ្វី អោយត្រូវតាមច្បាប់តុលាការ ច្បាប់តុលាការរង់ចាំពាក្យបណ្តឹងគ្រប់ពេលវេលា។

**៣៩តែបើអ្នករាល់គ្នាចង់សួរពីដំណើរណាទៀត នោះត្រូវតែបាន សំរេចក្នុងជំនុំ ដែលប្រជុំតាមច្បាប់វិញ ៤០ដ្បិតខ្លាចក្រែងយើង ត្រូវទោសជាពួកបះបោរ ដោយព្រោះរឿងដែលកើតមកនៅថ្ងៃ នេះ ដ្បិតគ្មានហេតុណាមួយ ដែលយើងអាចនឹងដោះសាពីការ ប្រជុំនេះបានទេ ៤១កាលមានប្រសាសន៍សេចក្តីទាំងនេះរួចហើយ នោះលោកឱ្យគេទៅវិញទៅ (កិច្ចការ១៩:៣៩-៤១)។**

លោកភ្លូឈួយសួរថា បើមានបញ្ហាអ្វីដែលចង់យកមកអោយច្បាប់ដោះស្រាយ សូមធ្វើអោយមានសណ្តាប់ធ្នាប់ត្រឹមត្រូវ។ លោកភ្លូឈួយប្រាប់ដល់អ្នកដឹកនាំក្រុម បាតុករថា ដើម្បីដោះស្រាយរឿងនេះ អ្នករាល់គ្នាត្រូវទម្លាក់បដាចុះ រួចហើយឈប់ ដើរស្រែកជំទាលពេញទីក្រុងទៀតទៅ។ បើនៅតែធ្វើយ៉ាងដូច្នេះទៀត យើងនឹងចោទ ប្រកាន់ដល់អ្នកដឹកនាំថា នាំគ្នាបះបោរទាស់នឹងរាជការរ៉ូម។ ការបះបោរទាស់នឹង រាជការរ៉ូម មានគ្រោះថ្នាក់ខ្លាំងណាស់។ ហេតុការណ៍ដែលយើងឃើញ នៅក្នុងគម្ពីរ នេះហាក់ដូចជាមិនខុសអំពីស្ថានភាព ដែលមនុស្សសព្វថ្ងៃចូលចិត្តធ្វើបាតុកម្មនោះទេ។

បន្ទាប់ពីលោកមានប្រសាសន៍រួចហើយ លោកភ្លូឈួយក៏បំបែកក្រុមបាតុករ។ ក្រុមបាតុករនាំគ្នាធ្វើអោយខូចខាតទ្រព្យសម្បត្តិសាធារណៈជាច្រើន។ ឥឡូវកិច្ចរបស់ សាវ័កប៉ុលនៅទីក្រុងអេភេសូរបានចប់សព្វគ្រប់ហើយ។ លោកចាកចេញពីទីក្រុង អេភេសូររួចហើយ ធ្វើដំណើរត្រឡប់ទៅស្រុកម៉ាសេដូនវិញ។

# ជំពូក ២០

*អារម្ភកថា ការបញ្ចប់ដំណើរបេសកកម្មលើកទីបី*

*សាវ័កប៉ុលចុះទៅស្រុកម៉ាសេដូន*

បន្ទាប់ពីបទពិសោធន៍ ដែលសាវ័កប៉ុលបានជួបប្រទះនៅទីក្រុងអេភេសូរ លោកបន្តធ្វើដំណើរទៅស្រុកម៉ាសេដូន ដោយឡែកគឺទៅទីក្រុងភីលីព រួចហើយត្រឡប់មកទីក្រុងទ្រអាស និងក្រុងមីលេតវិញ។ ពួកអ្នកចាស់ទុំក្រុមជំនុំនៅព្រះវិហារទីក្រុងអេភេសូរ បានជូនដំណើរសាវ័កប៉ុលរហូតមកដល់ទីក្រុងមេលេត រួចហើយក៏លាសាវ័កប៉ុលនៅទីនោះ។

## សាវ័កប៉ុលចុះទៅស្រុកម៉ាសេដូន

**[១]លុះក្រោយដែលការចលាចលនោះបានស្ងប់ស្ងាត់ហើយ នោះ**
**ប៉ុលហៅពួកសិស្សមក រួចលាគេ ចេញទៅឯស្រុកម៉ាសេដូនវិញ**
**[២]កាលគាត់បានដើរកាត់ដែនស្រុកទាំងនោះ ហើយអធិប្បាយទូន្មានជាច្រើន ដល់ពួកសិស្ស នោះគាត់បានដល់ទៅស្រុកក្រេក (កិច្ចការ២០:១-២)។**

នៅពេលលោកធ្វើដំណើរកាត់ស្រុកម៉ាសេដូន លោកឈៀងចូលសួរសុខទុក្ខ ពួកជំនុំនៅទីក្រុងអាថែន និងទីក្រុងកូរិនថូស។

**[៣]ក៏នៅស្រុកនោះអស់៣ខែ តែកាលគាត់រៀបនឹងចុះសំពៅទៅឯស្រុកស៊ីរី នោះពួកសាសន៍យូដា គេគិតល្បិចទាស់នឹងគាត់បាន ជាគាត់សំរេចនឹងទៅតាមស្រុកម៉ាសេដូនវិញ [៤]មានសូប៉ាត្រុស ដែលនៅក្រុងបេរា អើរីស្តា នឹងសេគុនដុស ពីពួកថែស្សាឡូនីច កៃយុស នឹងធីម៉ូថេ ពីក្រុងឌើបេ ហើយទីឃីកុស នឹងទ្រភីម ពីស្រុកអាស៊ី គេជូនដំណើរទៅត្រឹមស្រុកអាស៊ី (កិច្ចការ២០:៣-៤)។**

ឈ្មោះរបស់ពួកអ្នកជឿទាំងអម្បាលមាណ ដែលរៀបរាប់នៅក្នុងខខាងលើ សុទ្ធតែជាអ្នកដែល ជឿព្រះអម្ចាស់យេស៊ូវ តាមរយៈការផ្សាយដំណឹងល្អរបស់សាវ័ក ប៉ុល។ ឥឡូវ សាវ័កប៉ុលមានមនុស្សច្រើនណាស់ ដែលចូលរួមដំណើរបេសកកម្មជាមួយ លោក។ មនុស្សទាំងនោះសុទ្ធតែជាបេសកជន ដែលចេញទៅបម្រើព្រះអម្ចាស់យេស៊ូវ គ្រីស្ទ។

សូមជ្រាបថា នៅពេលដែលសាវ័កប៉ុលធ្វើដំណើរកាត់ស្រុកក្រេក និង ស្រុកម៉ាសេដូន លោកបានចូលទៅសួរសុខទុក្ខក្រុមជំនុំទាំងអម្បាលមាណ ដែលលោក

បានបង្កើតនៅក្នុងពេលដែលលោកធ្វើដំណើរបេសកកម្មលើកទីមួយ និងលើកទីពីរ។ លោកចុះសំចតនៅទីក្រុងអាថែន និងទីក្រុងកូរិនថូស។ ម្យ៉ាងទៀតលោកក៏ចុះនៅទីក្រុងថែស្សាឡូនីច ក្រុងបេរា និងក្រុងភីលីពដែរ។ លោកធ្វើដំណើរសារដានឡើងវិញដើម្បីសួរសុខទុក្ខដល់ពួកជំនុំទាំងអស់ ដែលលោកបានបង្កើតនៅក្នុងទ្វីបអឺរ៉ុប។ ដំណើរបេសកកម្មលើកទីបីរបស់លោក លោកសង្កត់ធ្ងន់នៅលើក្រុមជំនុំដែលទើបនឹងបង្កើតនៅក្នុងទ្វីបអឺរ៉ុប។

យើងស្លេះការសិក្សាគម្ពីរកិច្ចការត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"